មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសន៍ជាមួយឈ្មោះ ខិ មិល ភេទស្រី
## មុខងារសម័យខ្មែរក្រហមៈ កងនារី
## រស់នៅភូមិទំនប់ដាច់ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ
## ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣
## សម្ភាសន៍ដោយៈ ឡុង ដានី
## ០០:៤២:១៧
## ២១ទំព័រ

ដានីៈ លោកយាយឈ្មោះពេញតែម្តង ឈ្មោះអីទៅ?

មិលៈ ឈ្មោះ ខិ មិល ។

ដានីៈ ខិ មិល?

មិលៈ ចា៎!

ដានីៈ អាយុប្រហែលប៉ុន្មានលោកយាយ?

មិលៈ អត់ដឹងទេ ខ្ញុំវាអត់ដឹង ។

ដានីៈ អត់ដឹង?

មិលៈ ចា៎!

ដានីៈ កើតតាំងពីជំនាន់ណាទៅ?

មិលៈ អីចឹងបានថាទៅស្រុកហ្នឹងអត់ដឹង អត់បានសួរបងផង បងចាស់ហើយអាយុ៧៥ហើយ ។

ដានីៈ លោកយាយប្អូនប្រហែលប៉ុន្មានឆ្នាំ?

មិលៈ ខ្ញុំអេ៎?

ដានីៈ បាទ! ប្អូនគាត់ប៉ុន្មានឆ្នាំ?

មិលៈ ខ្ញុំមិនដឹងប៉ុន្មានទេ បើបង៧៥ហើយ ។

ដានីៈ បង៧៥ តែលោកយាយកើតក្រោយគាត់ប្រហែលប៉ុន្មានឆ្នាំ? គាត់អាយុប៉ុន្មានហើយបាន លោកយាយកើត?

មិលៈ វាអត់ដឹង ។

ដានីៈ លោកយាយកើតជំនាន់សម្តេចឪ ឬក៏មុនសម្តេចឪ?

មិលៈ អាចមុន ។

ដានីៈ មុនសម្តេចឪទៀត?

មិលៈ មុនសម្តេចឪគាត់ហ្នឹងអេ៎?

ដានី៖ បាទ!

មិល៖ អត់ទេ ក្រោយទេ។

ដានី៖ ក្រោយសម្តេចឪ?

មិល៖ ចា៎! តែមិនអាយុប៉ុន្មានៗវាមិនដឹង បើម៉ែអស់ហើយមានទៅសួរពីណា បើសួរបងប្អូន បងប្អូននៅបានស្រណុកសួរ។

ដានី៖ ប្តីលោកយាយគាត់ឈ្មោះអីទៅ?

មិល៖ ប្តីខ្ញុំរឿន។

ដានី៖ អីរឿន ដែរ?

មិល៖ រឿន នៅខាងភ្នំពេញ ខាងកណ្តាលត្បូងភ្នំពេញ គាត់ស្លាប់ហើយ។

ដានី៖ ត្រកូលអី រឿន? លោកយាយឈ្មោះ ខិ មិល?

មិល៖ ចក់ រឿន។

ដានី៖ គាត់ស្លាប់តាំងពីអង្កាល់?

មិល៖ ស្លាប់៣០ឆ្នាំ។

ដានី៖ ស្លាប់ពេលលោកយាយមកដល់នេះហើយ ឬក៏?

មិល៖ ខ្ញុំមិនទាន់មកនៅនេះទេ គាត់ស្លាប់នៅភ្នំដងរែកនោះ។

ដានី៖ នៅភ្នំដងរែកពេលដែលយួនចូលហើយ?

មិល៖ ចា៎! ស្លាប់នឹងគ្រុន នឹងឈឺ។

ដានី៖ លោកយាយមានកូនប៉ុន្មាននាក់ទៅ?

មិល៖ កូនតែ២ហ្នឹង។

ដានី៖ កូន២នាក់ ស្រី?

មិល៖ ស្រីមួយ ប្រុសមួយហ្នឹង។

ដានី៖ មានតែ២នាក់ទេអីចឹង? ធំអស់ហើយ?

មិល៖ មានប្តី មានប្រពន្ធអស់ហើយ។

ដានី៖ លោកយាយជនជាតិអីគេទៅ?

មិល៖ ខ្ញុំកាវែត ប្តីខ្ញុំខ្មែរក្រោម។

ដានី៖ ប្តីជនជាតិខ្មែរក្រោម?

មិល៖ ចា៎! នៅខេត្តកណ្តាល។

ដានី៖ ជួបគ្នាការពីអង្កាល់ទៅ?

មិលៈ ជួបគ្នាសម័យ៧៩ ។

ដានីៈ ជួបគ្នាសម័យ៧៩ក៏ការ?

មិលៈ ហ្នឹងហើយ ។

ដានីៈ លោកយាយជនជាតិកាវ៉ែត ស្រុកកំណើតនៅភូមិអីទៅ?

មិលៈ រតនគិរី ។

ដានីៈ ភូមិអីនៅរតនគិរី?

មិលៈ ស្ទឹងត្រែងនោះ ។

ដានីៈ ខ្ញុំស្គាល់រតនគិរីខេត្ត តែនៅខាងភូមិ-ឃុំ?

មិលៈ ភូមិខ្ញុំនៅខាងម្តុំ តាឡៃ បរកែវ ។

ដានីៈ តាឡៃ?

មិលៈ តែខេត្ត ទីរួមស្រុកស្ទឹងត្រែងនោះឯង ។

ដានីៈ មិនមែនរតនគិរីទេ?

មិលៈ ហ្នឹងហើយ ។

ដានីៈ រតនគិរី ឬស្ទឹងត្រែង?

មិលៈ ដែលខេត្ត ទីរួមស្រុក ។

ដានីៈ ទីរួមស្រុកអីគេ?

មិលៈ ខេត្តស្ទឹងត្រែង ។

ដានីៈ កន្លែងលោកយាយកើតនៅតាឡៃ?

មិលៈ ចា៎! ទេ ខ្ញុំកើតមិនមែននៅតាឡៃទេ ខ្ញុំកើតនៅឯណានោះស្រុកលាវ ។

ដានីៈ កើតនៅស្រុកលាវទេ?

មិលៈ ចា៎!

ដានីៈ ប៉ុន្តែមករស់នៅ?

មិលៈ មកនៅរស់នៅកន្លែងតាឡៃបាក់កែហ្នឹងធំៗអស់ហើយ ។

ដានីៈ តាឡៃបាក់កែ អាហ្នឹងគេហៅស្រុកអីគេ? ស្រុកសៀមបាង?

មិលៈ ហ្នឹងហើយស្រុកសៀមបាង ខេត្តស្ទឹងត្រែង ។

ដានីៈ ស្រុកសៀមបាង ខេត្តស្ទឹងត្រែង?

មិលៈ ចា៎!

ដានីៈ ចុះលោកយាយថាខេត្តរតនគិរី?

មិលៈ  រតនគិរីខេត្តខ្ញុំហ្នឹងឯង បើមណ្ឌលគិរីខាងបាងលុង ហ្នឹងផ្សេង រតនគិរីខ្ញុំនេះឯង ។

ដានីៈ  ប៉ុន្តែលោកយាយថាមករស់នៅតាវែង បាក់កែ ។

មិលៈ  អាហ្នឹងយើងរស់នៅសម័យយើងធ្វើស្រែ ធ្វើចំការ ។

ដានីៈ  តែពីក្មេងៗនៅជាមួយឪពុកម្តាយនៅណាទៅ?

មិលៈ  ហ្នឹង កន្លែងហ្នឹង ។

ដានីៈ  កន្លែងណា?

មិលៈ  កន្លែងតាវែងហ្នឹង ។

ដានីៈ  កាលហ្នឹងឪពុកម្តាយ?

មិលៈ  ឪពុកម្តាយខ្ញុំនៅ ដល់ខ្ញុំរត់មកនេះ អត់ដឹងថាមួយចំនួនកើតសង្គ្រាម ។

ដានីៈ  ឪពុកឈ្មោះអីទៅ?

មិលៈ  ឪពុកខ្ញុំឈ្មោះប៉ាំង មិល ។

ដានីៈ  ប៉ាំង មិល?

មិលៈ  ចាំ! ជីដូនជីតាខាងឪពុក ។

ដានីៈ  តែលោកយាយឈ្មោះ ខិ មិល?

មិលៈ  ខិ ហ្នឹងតា ។

ដានីៈ  ហើយមិល ឈ្មោះលោកយាយ?

មិលៈ  ហើយប៉ាំងហ្នឹងឈ្មោះពុក ខ្ញុំដាក់តែឈ្មោះតា ។

ដានីៈ  ប៉ាំងឈ្មោះឪពុក គាត់ស្លាប់យូរនៅ?

មិលៈ  មិនទាន់ស្គាល់ពុកផង លឺតែគេថាពុក ខ្ញុំនៅក្នុងពោះម៉ែ បានអីស្គាល់ពុកផង ។

ដានីៈ  ចុះម្តាយ?

មិលៈ  ម្តាយឈ្មោះ ឆប ។

ដានីៈ  ហើយគាត់នៅរស់ ឬក៏ស្លាប់ហើយ?

មិលៈ  អស់ហើយ ពុកក៏ងាប់ ម៉ែក៏ងាប់ យាយក៏ងាប់ ។

ដានីៈ  ឪពុកជនជាតិអីដែរ?

មិលៈ  កាវ៉ែតដូចគ្នា ។

ដានីៈ  ចុះម្តាយ?

មិលៈ  ម្តាយកាវ៉ែត ។

ដានីៈ  ចុះលោកយាយមានបងប្អូនប៉ុន្មាននាក់?

មិលៈ ខ្ញុំតែ២នាក់ទេ ។

ដានីៈ បងប្អូនបង្កើតតែ២នាក់ទេ?

មិលៈ ចា៎! តែ២នាក់ហ្នឹងស្រីទាំង២ ។

ដានីៈ បងគាត់ឈ្មោះអី? បងលោកយាយ?

មិលៈ ឈ្មោះមា ។

ដានីៈ បងប្អូន?

មិលៈ មា៉ មិល ។

ដានីៈ បងស្រីឈ្មោះ មា៉ លោកយាយឈ្មោះ មិល ។

មិលៈ ប្អូនឈ្មោះមិល ។

ដានីៈ មិល ហ្នឹងលោកយាយ?

មិលៈ ខ្ញុំពៅគេ ។

ដានីៈ តែពីរនាក់អីចឹង?

មិលៈ ចា៎!

ដានីៈ ស្រីទាំងពីរ បងឈ្មោះមា ហើយលោកយាយឈ្មោះមិល?

មិលៈ ចា៎!

ដានីៈ មា អាយុ៧៥ហើយ ។

មិលៈ ស្លាប់បាត់ហើយមិនដឹងកូនអើយ ។

ដានីៈ ម៉េចបានដឹងថាគាត់អាយុ៧៥?

មិលៈ ខ្ញុំទៅសារនេះហ្នឹង ។

ដានីៈ ទៅគាត់និយាយប្រាប់ថាគាត់អាយុ៧៥?

មិលៈ ហ្នឹងហើយ បើគាត់ចាស់ហើយ ស្កូវឡើងដើរឡើងកោង១ ។

ដានីៈ តែលោកយាយអត់ដឹងអាយុខ្លួនឯងប៉ុន្មាន?

មិលៈ ខ្ញុំអត់ បើគាត់វង្វេងវង្វាន់ដែរ បើគាត់ចាស់ សួរទៅអត់ដឹង ។

ដានីៈ ក្រែងកើតឆ្ងាយពីគ្នា ប្អូនគ្នា២-៣ឆ្នាំ ១ឆ្នាំ?

មិលៈ បែបអីចឹងដឹង ចាំមើលគេយកទៅធ្វើកុមារហ្នឹងខ្ញុំទើបតែអាយុ១០ឆ្នាំ គេយកទៅ ។

ដានីៈ ពីណាយកទៅ?

មិលៈ អង្គការស្អីទេ អត់ដឹងដែរ តូចៗអាយុ១០ឆ្នាំ ។

ដានីៈ កាលក្មេងៗបានទៅសាលារៀនសូត្រទេ?

មិលៈ បានទៅ ។

ដានីៈ អានអក្សរដាច់ទេ?

មិលៈ អត់ ពីមុននៅក្មេងអានដាច់ ដល់ចាស់ទៅយើងធ្វើបដិវត្តន៍យើងអត់បានរៀន ស្ដាយ បើសិនខ្ញុំចេះអក្សរនោះ សៀវភៅលោកខ្ញុំរៀនធម៌តែខ្ញុំអត់ចេះ ។

ដានីៈ លោកយាយកាលពីក្មេងៗច្រើននិយាយភាសាអី?

មិលៈ អាំ?

ដានីៈ ច្រើននិយាយជាមួយគ្នាភាសារអី?

មិលៈ សារមុនយើងនិយាយតែជនជាតិយើង តែឥឡូវយើងនៅរួមរស់ជាមួយខ្មែរប៉ុន្មានឆ្នាំហើយកូនឯង ៥០ឆ្នាំហើយមិនដឹង ។

ដានីៈ តែកាលមុនយើងនិយាយភាសាកាវែត តែលោកយាយនៅចេះ នៅចាំនិយាយភាសាកាវែតអត់?

មិលៈ អត់សូវចាំដែរហ្នឹង ខ្ញុំទៅហ្នឹងបិ បី ចាំមួយម៉ាត់ៗទេ ។

ដានីៈ និយាយឲ្យខ្ញុំស្ដាប់បន្តិចបានទេ?

មិលៈ មិនដឹងនិយាយម៉េចទេលោកកូន ។

ដានីៈ ឈ្មោះអីគេថាម៉េចទៅ?

មិលៈ ឈ្មោះអី ។ ដូចថាពូ មានបង មានប្អូន ។ បើបងគេហៅអុ ។

ដានីៈ ប្អូន?

មិលៈ ប្អូនហ្នឹង អស់ ។

ដានីៈ អស់?

មិលៈ ហ្នឹងហើយ ខ្ញុំចាំតែមួយម៉ាត់ៗទេ ។

ដានីៈ ខាននិយាយគ្នាយូរ?

មិលៈ ក្រៅពីហ្នឹងអត់ទេ ។

ដានីៈ និយាយតែខ្មែរ?

មិលៈ និយាយតែខ្មែរ ឡើងភ្នំដងរែកនេះនៅនេះ ភ្នំឱរ៉ាល់ ភ្នំអារញ្ញអីហ្នឹង ខ្ញុំនៅឡើងចង់ចាស់ចាស់កោងខ្នងអស់ដែលហ្នឹង ខ្ញុំដើរហ្នឹងមិនមែនដើរតិចខែ តិចឆ្នាំទេ ។

ដានីៈ កាលពីក្មេងៗអត់ដែលទៅសាលារៀនទេ?

មិលៈ ទេ កាលពីគេមិនទាន់យកទៅភូមិភាគខ្ញុំទៅ បងថ្លៃខ្ញុំគ្រូចាងហ្វាង គ្រូបង្រៀនដែរ ដល់ម៉ែលំបាកពេក ម៉ែមេម៉ាយ ក៏ខ្ញុំឈប់រហូតតាំងពីហ្នឹងមករហូតទល់សព្វថ្ងៃ នឹកឃើញអាណិតម៉ែ ធ្វើចំការតែឯង ម៉ែមេម៉ាយកំព្រាដូចខ្ញុំដែរ អត់កូន កូនមានតែពីរគ្រាប់ ។

ដានី៖ អីចឹងឈប់ទៅជួយធ្វើចំការ?

មិលៈ ធ្វើចំការម៉ែអីចឹងទៅ ដល់ពេលអីចឹងទៅមានអង្គការគេហ្នឹងមកសុំម៉ែហ្នឹងទៅរៀនភូមិភាគមជ្ឈិម ទៅៗរហូតដល់ធំៗអីចឹងទៅ បានអង្គការហ្នឹងឲ្យធ្វើនារី ។

ដានី៖ ហើយម៉េចទៀត?

មិលៈ ធ្វើនារីមកការជាមួយកងទ័ព ទ័ពខ្លះគេនៅភ្នំពេញ ខ្លះគេនៅព្រៃវែង ខ្លះគេនៅក្រចេះ ស្ទឹងត្រែង វាច្របល់គ្នាអស់ហើយ យកទៅសម័យហ្នឹង ។

ដានី៖ យកជាមួយពីណាគេ? គេឲ្យលោកយាយការជាមួយពីណា?

មិលៈ ការជាមួយប្ដីខ្ញុំឈ្មោះរឿន ហ្នឹង ។

ដានី៖ ការនៅណា?

មិលៈ ការនៅស្រុក ។

ដានី៖ នៅស្រុកណា?

មិលៈ ការនៅសៀមបាង ។

ដានី៖ កាលហ្នឹងគាត់ធ្វើអី? គាត់ធ្វើកងទ័ព?

មិលៈ ទ័ព ។

ដានី៖ ទ័ពនៅសៀមបាងហ្នឹង?

មិលៈ ហ្នឹងហើយ ។

ដានី៖ កាលហ្នឹងលោកយាយធ្វើអីទៅ?

មិលៈ ខ្ញុំធ្វើនារី ។

ដានី៖ នារីនៅក្នុងកងទ័ពហ្នឹងដែលឬអត់ទេ?

មិលៈ ហ្នឹងហើយ ធ្វើ ។

ដានី៖ កាលហ្នឹងនារីនៅក្នុងកងទ័ពពីណាគេ? ទ័ពរបស់ពីណា?

មិលៈ មិនដឹងកងទ័ពពីណាទៀតកូន ខ្ញុំមិនស្គាល់ដែរ ។

ដានី៖ មេគេឈ្មោះអី?

មិលៈ មេហ្នឹងក្សត់អស់ហើយ ។

ដានី៖ ពីណាគេក្សត់អស់ហើយហ្នឹង?

មិលៈ មិនដឹងឈ្មោះតាអី ខ្ញុំភ្លេចដែលយូរហើយ ។

ដានីៈ ក្បត់តាំងពីអង្គាល់?

មិលៈ ក្បត់តាំងពីយើងរត់មកហ្នឹង គេបាញ់ចោលទៅ ។

ដានីៈ ពីណាគេ? ឈ្មោះអីទៅ?

មិលៈ វាភ្លេចឈ្មោះ វាអត់នឹកឃើញ វាយូរហើយ យើងមិននឹកឃើញរំលឹករឿងអីចឹងៗ អត់ ។

ដានីៈ ស្គាល់តាបុត អត់?

មិលៈ តាបុត មិនមែននៅនេះទេ គេនៅខាងបាងលុង តាបុត ឈ្មោះតាយ៉ន់ ។

ដានីៈ រូមាំង យ៉ន់?

មិលៈ តាយ៉ន់ ។

ដានីៈ ស្គាល់គាត់ដែរ?

មិលៈ ស្លាប់បាត់ហើយ ។

ដានីៈ តាយ៉ន់ គាត់ជនជាតិដែល?

មិលៈ ជនជាតិ ។

ដានីៈ ជនជាតិអីហ្នឹង?

មិលៈ ជនជាតិខាងលាវ ច្រើនណាស់កងទ័ពកាលនេះ ។

ដានីៈ អីចូលធ្វើអង្គការ គេហៅធ្វើតាំងពីជំនាន់ណាមក?

មិលៈ មិនដឹងជំនាន់ណាទៀត ខ្ញុំវាភ្លេចភ្លាំងអស់ហើយ មិនមែននៅតិចឆ្នាំទេ ខ្ញុំខាងរតនគិរីតែកាលនេះគេចូលច្រើន ខាងជនជាតិការ៉ែតគេចូលច្រើន ឥឡូវគេទៅស្រុកអស់ហើយនៅតែខ្ញុំ ។

ដានីៈ កាលហ្នឹងគេចូលប៉ុន្មាននាក់ទៅ?

មិលៈ រាប់រយ រាប់ពាន់ ។

ដានីៈ នៅភូមិរបស់លោកយាយ?

មិលៈ កាលជំនាន់អ៊ុនគាក់ចុះគេទៅផ្ទះអស់ហើយ នៅតែខ្ញុំទេ ។

ដានីៈ ម៉េចបានលោកយាយអត់ទៅផ្ទះ?

មិលៈ ទៅអី បើអត់ធ្លាប់ទៅស្រុក ខានយូរហើយនឹកឃើញនៅនឹងគេឯង ។

ដានីៈ អត់ចង់ទៅនៅស្រុកវិញ?

មិលៈ ចា៎! ទៅស្រុក ទៅផ្ទះអីបើយើងមេម៉ាយទៅរកស៊ីអី នៅនេះយើងធ្លាប់ធ្វើស្រែចំការ ខ្ញុំមិនដែលបានទៅរកស៊ីទេរាល់ថ្ងៃហ្នឹង ការកូន ការចៅហើយខ្ញុំបំរើវត្ត ។

ដានី៖ ដល់ពេលលោកយាយនៅអីចឹង មិនលែងធ្វើតាមដូចជនជាតិកាវែតគេមានប្រពៃណី សាសនាផ្សេង?

មិល៖ ទេបើទៅស្រុកមាន បើនៅនេះអត់មានទេ ទៅតាមខ្មែរ ខ្មែរធ្វើម៉េចយើងធ្វើតាមខ្មែរ ប្រពៃណីខ្មែរ ។

ដានី៖ ធ្វើតាមខ្មែរតាំងពីអន្លង់វែងមក?

មិល៖ បើស្រុកខាងខ្ញុំគេធ្វើចំការ កាប់ចំការអីហ្នឹងឯង បួតស្រូវ អត់មានច្រូតដូចខ្មែរទេ ស្រូវបួត

ដានី៖ តែលោកយាយកាលនៅស្រុកអត់មានលោកទេ?

មិល៖ មាន តែលោកឆ្ងាយ លោកមកខាងស្ទឹងត្រែង សៀមបាង ។

ដានី៖ តែលោកយាយធ្លាប់ទៅវត្តដែលកាលមុន?

មិល៖ អត់ដែលបានទៅវត្តទេ ទើបឥឡូវខ្ញុំចាប់ផ្តើមជួបព្រះពុទ្ធ ឥឡូវនេះជួបតែព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ខ្ញុំនៅនោះតាំងពីអាយុ៣៥ ការកូនហើយនេះ ខ្ញុំចូលវត្ត ខ្ញុំមេម៉ាយ ឥឡូវ៣០ឆ្នាំហ្នឹង តាំងពីផ្តាច់ខ្លួនមកខ្ញុំមកនៅនេះ ខ្ញុំបាននៅជាមួយព្រះសង្ឃ ។

ដានី៖ បើតាមជនជាតិរបស់លោកយាយមិនមានព្រះសង្ឃទេ ។

មិល៖ មានតែវានៅឆ្ងាយ ។

ដានី៖ តែយើងនៅស្រុកនោះយើងសែន ។

មិល៖ អត់មានទេ ។

ដានី៖ ដល់លោកយាយមកនេះអត់សែន?

មិល៖ អត់ទេ ដូចថាចាប់ដៃគ្នាកាប់ជ្រូក កាប់មាន់ ដូចថាជប់លាង ដូចគេជប់លាងអីចឹង ហ្នឹងហើយខាងខ្ញុំ ស្មាទោស ។

ដានី៖ ខាងលោកយាយកាលមុននៅជាមួយអង្គការច្រើនដែរ?

មិល៖ អត់បានច្រើនទេ ។

ដានី៖ ចូលជាមួយអង្គការច្រើនទេ កាលនៅសៀមបាង?

មិល៖ អត់ទេ អត់មានអង្គការណាច្រើន តែមួយហ្នឹងឯង ។

ដានី៖ អ្នកស្រុក អ្នកភូមិនៅជាមួយលោកយាយដែរ?

មិល៖ ហ្នឹងហើយ អ្នកមុនៗគេទៅអស់ហើយ នៅតែខ្ញុំ នៅជាមួយកូនអីនេះ ។

ដានី៖ ជនជាតិកាវែត ជនជាតិភាគច្រើនគេទៅ?

មិល៖ នេះចំរុះ ។

ដានី៖ គេទៅណាវិញអស់ទៅ?

មិលៈ គេទៅស្រុក ទៅប្រទេសគេអស់ហើយ ។

ដានីៈ ម៉េចបានលោកយាយអត់ទៅ? នៅសល់ម្នាក់ឯង?

មិលៈ ខ្ញុំអត់ទៅទេ ។

ដានីៈ មានអ្នកផ្សេងនៅដែរ? ឬក៏នៅតែលោកយាយម្នាក់ទេ?

មិលៈ មានអ្នកខ្លះនៅ មិនអត់ទេអ្នកនៅ តែយើងមើលមិនឃើញ គេនៅគ្រប់កន្លែងតាំងពីថៃ សុទ្ធតែខាងខ្ញុំខ្លះ ខាងគេខ្លះ ខាងខ្ញុំខ្លះ តែមនុស្សខ្ញុំមនុស្សល្ងង់អត់ដឹងអីទេ អ៊ីៗក៏មិនដឹងដែរ អីចឹងបានកសាងខ្លួនឯងជាតិណាៗកុំឲ្យខ្ញុំល្ងង់ល្ងិតដូចជាតិនេះ បានខំមកបម្រើព្រះសង្ឃ ។

ដានីៈ លោកយាយនៅចាំទេពេលដែល កាលលោកយាយនៅស្រុកអាយុ១០ឆ្នាំ លោកយាយអង្គការហៅឲ្យមកធ្វើការងារអីខ្លះទៅ?

មិលៈ ខ្ញុំនៅពីតូចៗ ដល់ពេលអាយុ១០ឆ្នាំ កាលហ្នឹងអង្គការមិនដឹងអង្គការអីទេ គេដើរសុំតាមភូមិ ដើរសុំកុមារតាមភូមិ គេយកទៅបង្រៀនដូចថាកាត់ដេរ បង្រៀនសិល្បៈ ដល់៧៩អ្នកណាធំៗគេបញ្ចុះទៅខាងនារី អ្នកណាតូចៗខាងសិល្បៈ មានតែប៉ុណ្ណឹងទេ ។

ដានីៈ ចុះលោកយាយនៅខាងណា? ខាងនារី ឬខាងសិល្បៈ?

មិលៈ ខ្ញុំនៅខាងនារីនេះ ។

ដានីៈ អត់មានលេងសិល្បៈទេ?

មិលៈ អត់ ។ នៅតូចៗហាត់ដែរហ្នឹង ។

ដានីៈ ហាត់សិល្បៈដែលកាលនៅតូចៗ?

មិលៈ មនុស្សតូចៗអ្នកណាទៅដឹង ប៉ុនចៅខ្ញុំរាល់ថ្ងៃនេះអត់ដឹងអីទេ ដឹងតែពីសប្បាយ ។

ដានីៈ ហើយធ្វើអីខ្លះទៅកាលនៅនារី?

មិលៈ អត់ធ្វើអីទេ កាប់ចំការ ជិរះតាមសាលាដែលកុមារ អត់ធ្វើអីទេ រាល់ថ្ងៃពីមុនៗ អូនឯងនៅខាងណា ។

ដានីៈ លោកយាយកាលនៅខាងសៀមបាង កាលហ្នឹងនៅក្នុងកងនារីមានគ្នាច្រើន ហើយភាគច្រើនជាជនជាតិហ្នឹង?

មិលៈ ជនជាតិហ្នឹងអត់មានលាយខ្មែរទេ សុទ្ធតែពួកជនជាតិទាំងអស់ ដូចជនជាតិទំពួន, កាវែតជនជាតិចារាយ, គ្រឹង ដល់មកនៅជាមួយខ្មែរទើបច្រលំអស់ហើយ មិនដឹងអ្នកណាគ្រឹងមិនដឹងអ្នកណាលាវ មិនដឹងអ្នកណាជនជាតិណា ។

ដានីៈ ដូចលោកយាយជនជាតិកាវែតអីចឹង ជាមួយជនជាតិផ្សេងទៀតនិយាយគ្នាស្តាប់បានដែរ?

មិលៈ ស្តាប់អត់បានទេ អាមួយនិយាយផ្សេង មិនមែននិយាយដូចខ្មែរណា៎ កុំថាជនជាតិដូចគ្នា អត់ទេ ខុសគ្នា ។

ដានីៈ លោកយាយម៉ិញមានប្រសាសន៍ ដល់ពេលណាគេហៅឡើងមកភូមិភាគ?

មិលៈ យើងតូចៗកុមារ ធំជាងនេះប៉ុនមីធំនេះ ។

ដានីៈ ១០ឆ្នាំជាង?

មិលៈ ប៉ុណ្ណឹងគេដើរសុំតាមផ្ទះ ។

ដានីៈ ខាងខ្មែរក្រហមហ្នឹងគេដើរសុំ?

មិលៈ មុនខ្មែរក្រហមទៀត មុនខ្មែរក្រហម៣ឆ្នាំ ។

ដានីៈ មុនខ្មែរក្រហម៣ឆ្នាំហ្នឹងទៀត?

មិលៈ ចា៎!

ដានីៈ គេដើរសុំឲ្យមក?

មិលៈ គេមកសុំធ្វើកុមារ ។

ដានីៈ ដល់ពេលសុំធ្វើកុមារហ្នឹងនៅក្នុងស្រុកភូមិហ្នឹងដែរ ឬក៏គេផ្លាស់ឲ្យទៅណាផ្សេង?

មិលៈ ដូចផ្លាស់នៅនេះ ដូចថាធំៗគេដាក់ឲ្យធ្វើនារី យូរៗមានទ័ព កងទ័ពគេមកចលនាតាមភូមិគេស្រឡាញ់គេយកទៅ ធ្វើជាប្រពន្ធទៅ ។

ដានីៈ កាលហ្នឹងភូមិភាគគេនៅណាទៅ?

មិលៈ អត់ដឹងទេ ភូមិភាគមជ្ឈិមអត់ដឹងនៅណាទេ ខ្ញុំភ្លេចអស់ហើយឥឡូវនេះ មមីមមើមអស់ហើយចាស់ហើយ ដល់ចាស់យើងបែកពីភូមិ ពីស្រុកយូរហើយ ។

ដានីៈ កងទ័ពដែលទៅនៅ កងទ័ពរបស់កងពលណាទៅ?

មិលៈ កងពលសុទ្ធតែអ្នកនៅខេត្តកណ្តាល ។

ដានីៈ កងពលរបស់ពីណាធ្វើប្រធាន?

មិលៈ វាមិនដឹង សម័យហ្នឹងវាច្រលំច្រលាយគ្នាអស់ហើយ ។

ដានីៈ ដល់ពេលលោកយាយការហើយអត់ដឹងការឆ្នាំណា? ជិតនាទ់៣ឆ្នាំ?

មិលៈ ៧៩ហ្នឹង ។

ដានីៈ ការឆ្នាំ៧៩យួនចូលហ្នឹង?

មិលៈ ចា៎!

ដានីៈ យួនចូលការនៅ?

មិលៈ ការហើយក៏រត់មកនេះ ។

ដានី៖ ការហើយបានរត់?

មិលៈ រត់មកនៅភ្នំអារញ្ញ ភ្នំនេះ បានមកនៅស្រុកនេះ ។

ដានី៖ ការហើយម៉េចលោកយាយរត់? ម៉េចបានរត់ពីភូមិមក?

មិលៈ ឃើញគេដើរ ចេះតែដើរតាមគេ ។

ដានី៖ ម៉េចយើងអត់នៅក្នុងភូមិ?

មិលៈ នៅក្នុងភូមិអីបើប្ដីនៅលំដាត់ បរកែវ ហើយនេះគេបបួលរត់ៗតាមគេ ។

ដានី៖ អ្នកណាបបួលរត់?

មិលៈ មេគេហ្នឹង មេទ័ព ។

ដានី៖ ពីណាគេមេទ័ព?

មិលៈ មិនដឹងនៅណាណីទេ ឥឡូវងាប់អស់ខ្លះ ។

ដានី៖ ពីណាគេ? លោកយាយចាំឈ្មោះទេ?

មិលៈ អត់ចាំទេ មេទ័ពហ្នឹងបើងាប់អស់ខ្លះហើយមួយចំនួនធ្វើសគ្រាម ។

ដានី៖ នៅចាំឈ្មោះអ្នកស្លាប់ហ្នឹង?

មិលៈ អត់ដឹងទេ ឥឡូវនេះដឹងតែប្ដីខ្ញុំទេ ។

ដានី៖ ប្ដីលោកយាយនៅទ័ពកងពលណា?

មិលៈ នៅក្រោមគេទេ ។

ដានី៖ តែគាត់នៅជាមួយពីណាគេ?

មិលៈ ដូចជាកងពលអីទេ ភ្លេចបាត់ហើយ ដូចជាវរៈ១១, ១២ ។

ដានី៖ កងពលលេខប៉ុន្មាន?

មិលៈ អត់ដឹង ។

ដានី៖ ពីណាធ្វើប្រធានកងពល?

មិលៈ អត់ដឹងទេ ។

ដានី៖ មេគេធំ?

មិលៈ ខ្ញុំអត់ស្គាល់ទេមេ ។

ដានី៖ ដល់ពេលយួនចូលមកឲ្យរត់ៗតាមគេទៅ?

មិលៈ ហ្នឹងហើយ ។

ដានី៖ ទៅហ្នឹងអត់ជួបប្ដីទេ?

មិលៈ ជួប មកជួបនឹងភ្នំដងរែកហ្នឹង ។

ដានី៖ មកជួបនឹងភ្នំដងរែក អីចឹងវគ់បែកគ្នាទេ វត់ពីស្រុកមក?

មិល៖ បែកគ្នា បែកគ្នា៣ឆ្នាំ ។

ដានី៖ កាលហ្នឹងមានកូនទៅ?

មិល៖ អត់ទេ ។

ដានី៖ អត់ទាន់មានទេ?

មិល៖ ទើបនឹងមានឆ្នាំ៨០ នេះ ។

ដានី៖ ឆ្នាំ៨០ បានមាន?

មិល៖ ចាំ!

ដានី៖ ហើយពេលរត់មកជាមួយពីណាខ្លះទៅ?

មិល៖ ចំរុះ មិនដឹងខ្មែរ មិនដឹងគ្រឹង មិនដឹងទំពួន មិនដឹងចារាយ វាចំរុះគ្នា ទាំងអស់ហ្នឹង ។

ដានី៖ មកដល់ដងរែកនៅណាទៅ?

មិល៖ នៅតាមព្រៃហ្នឹង នៅតាមជាយដែនថៃ ។

ដានី៖ គេហៅអីជាយៗហ្នឹង?

មិល៖ អត់ដឹងទេ ។

ដានី៖ ដំបូង?

មិល៖ ខ្ញុំអត់ដឹងព្រោះខ្ញុំទើបតែមកដែរ មិនទាន់ស្គាល់ភូមិសាស្រ្តគេផង ។

ដានី៖ មិនមែនទៅខាងទន្លេល្ពៅទេ? មុំ៣?

មិល៖ ខាងទន្លេល្ពៅគ្រាន់តែភូមិតាំនោះ ភូមិថ្មី ។

ដានី៖ តែទៅនៅហ្នឹងអត់?

មិល៖ ខ្ញុំអត់ទៅទេឥឡូវនេះ ។

ដានី៖ តែមកដំបូងមាននៅហ្នឹងដែលអត់?

មិល៖ នៅ បងនេះក៏នៅ នៅជាមួយគ្នា ។

ដានី៖ នៅខាងទន្លេល្ពៅហ្នឹង?

មិល៖ ហ្នឹងហើយ ។

ដានី៖ ហើយបានជួបគ្រួសារវិញ?

មិល៖ នៅទន្លេល្ពៅហ្នឹង ។

ដានី៖ កន្លែង១០០១ហ្នឹង?

មិល៖ ចាំ! គាត់មកជួបខ្ញុំត្រឹមហ្នឹង ។

ដានី៖ ដល់ពេលជួបហើយលោកយាយទៅណាទៀតទៅ?

មិល៖ នេះមកនៅស្រុកនេះ ។

ដានី៖ ដល់ចេញពីទន្លេល្អៅមកនៅណា?

មិល៖ នេះនៅទំនប់ដាច់ ។

ដានី៖ អត់មាននៅលើភ្នំសិនទេ?

មិល៖ អត់ទេ ។

ដានី៖ មកនៅម៉េចកើតបើកាលហ្នឹងមិនទាន់នេះទេ?

មិល៖ ជាំស្វានេះ នៅក្នុងស្រុកថៃ ។

ដានី៖ ធ្លាប់ទៅនៅជាំស្វា ស្រុកថៃហ្នឹងដែរ?

មិល៖ ធ្លាប់ នោះ ។

ដានី៖ ដល់ពេលមកដល់ហ្នឹង លោកយាយមកនៅក្នុងកងពលណាវិញទៅ?

មិល៖ អត់មានកងពលទេ កងពលឆាប់អស់ហើយ ឆាប់ជាន់មីនអស់ហើយ ។

អ្នកជិតខាង៖ តាសារឿន ។

មិល៖ ណា?

អ្នកជិតខាង៖ តាសារឿន ។

មិល៖ តាសារឿន ឆាប់អស់ហើយ គេហៅឈ្មោះតាសារឿន (តា០៥) ឥឡូវគាត់ឆាប់អស់ហើយ ទាំងប្ដីអស់ហើយ ។

ដានី៖ លោកយាយនៅជាមួយគាត់?

មិល៖ ហ្នឹងហើយ ។

ដានី៖ នៅក្នុងកងពលគាត់?

មិល៖ កងពលណាផ្សេងទៀត តែខ្ញុំអត់ស្គាល់ បើគេឆាប់អស់ហើយ ខ្ញុំម៉េចដឹង ប្ដីខ្ញុំនៅរស់បានដឹង

ដានី៖ ដល់ពេលប្ដីអ៊ំស្លាប់ពីអន្លង់?

មិល៖ ស្លាប់៣០ឆ្នាំហើយ ។

ដានី៖ ស្លាប់ពេលនៅទន្លេល្អៅហ្នឹង?

មិល៖ ទេ ស្លាប់នៅជាំស្វា ។

ដានី៖ ស្លាប់នៅជាំស្វានេះទេ?

មិល៖ ចា៎! ស្លាប់បាន៣០ឆ្នាំ ឆ្នាំនេះ ។

ដានី៖ ដល់ពេលគាត់ស្លាប់ទៅលោកយាយអត់យកគ្រួសារអីទៀតទេ?

មិលៈ អត់ទេ ខ្ញុំអត់យក ខ្ញុំការកូន ការចៅហើយខ្ញុំមកនៅវត្ត បម្រើលោកទៅឲ្យបានបុណ្យ ។

ដានីៈ តាសារឿន ស្លាប់យូរហើយ?

មិលៈ យូរហើយ យូរតាំងពីមុនប្ដីខ្ញុំប្រហែល១ឆ្នាំចុះ ។

ដានីៈ លោកយាយនៅភូមិណា?

មិលៈ ភូមិហ្នឹង ភូមិទំនប់ដាច់ហ្នឹង ។

ដានីៈ លោកយាយនៅទំនប់ដាច់ហ្នឹង?

មិលៈ ចា៎! អានេះគេហៅភូមិទំនប់ដាច់ ។

ដានីៈ ផ្ទះលោកយាយនៅណា?

មិលៈ ផ្ទះខ្ញុំអត់មានទេ ខ្ញុំមកនៅវត្ត នេះផ្ទះខ្ញុំនៅនេះឥឡូវខ្ញុំរុះចេញហើយ ។

ដានីៈ មុននៅនេះ តែរុះចេញ?

មិលៈ ចា៎! រុះចេញមកនៅវត្ត ។

ដានីៈ ចុះកូនចៅ?

មិលៈ កូនចៅគេនៅនោះអូរឫស្សីឆ្ងាយដែរ ។

ដានីៈ ឆ្ងាយពីនេះ?

មិលៈ អូរឫស្សី-ទួលគ្រួសនោះ?

ដានីៈ អូរឫស្សី-ទួលគ្រួសខាងជាប់អន្លង់វែងនោះ?

មិលៈ ចា៎! គេទៅនៅដីថ្មី ។

ដានីៈ អត់ទៅនៅជាមួយកូនទេ?

មិលៈ តាមគាត់អី ខ្ញុំនៅជាប់នឹងលោក បើខ្ញុំចាស់ហើយ ។ បើយើងមិនធ្វើបុណ្យ ធ្វើទានម៉េចកូនឯងចាស់ហើយ ។

ដានីៈ កូនគាត់មកលេងដែលអត់?

មិលៈ ខែម៉ិន់សន់រដូវបានមក ឥឡូវនេះអត់មកទេ ។

ដានីៈ ចុះអត់នឹកចៅទេ?

មិលៈ នឹក នោះចៅមករៀន ។

ដានីៈ មករៀនហ្នឹងដែរ?

មិលៈ ចា៎!

ដានីៈ មកនៅជាមួយលោកយាយ?

មិលៈ ទេ អត់នៅជាមួយទេ ដល់ពេលរៀនហើយគេទៅម៉ែគេហើយ ។

ដានីៈ ដល់ពេលរៀនហើយគេទៅនៅជាមួយម៉ែគេវិញ?

មិលៈ ចាំ!

ដានីៈ លោកយាយជាជនជាតិកាវ៉ែត ជនជាតិលោកយាយភាគច្រើនពេលដែលក្រោយមក ដែលផ្ញើសមាហរណកម្មជាមួយរដ្ឋាភិបាលហើយ គេទៅស្រុកគេវិញអស់ទៅ?

មិលៈ ចាំ!

ដានីៈ ម៉េចបានលោកយាយនៅសល់តែម្នាក់ឯងអត់ព្រម?

មិលៈ ខ្ញុំវាអត់ចង់ទៅ ខ្ញុំចង់នៅជាមួយគេនេះ ហើយដីធ្លីខ្ញុំកាលខ្ញុំនៅមេម៉ាយ ខ្ញុំចាប់បាន៦-៧ប្លង់ដែរ ខ្ញុំនឹកឃើញស្តាយដី ទៅស្រុកគ្មានដីខ្ញុំនៅមិនបានទេ ។

ដានីៈ ឥឡូវដីលោកយាយមាន៦-៧ប្លង់ដែរ?

មិលៈ ដីអីនោះ ។

ដានីៈ ឯណា?

មិលៈ ដីកន្លែងស្រុកកំណើតខ្ញុំ នៅនេះអត់ទេ បានតែមួយប្លង់ម្នាក់ហ្នឹង ។

ដានីៈ លោកយាយដីនៅណាទៅ?

មិលៈ ដីអីទួលគ្រួស នៅអីអូរឫស្សី ។

ដានីៈ អូ! ដីលោកយាយនៅហ្នឹងទេ? ចាប់បាននៅហ្នឹង?

មិលៈ ចាំ ។

ដានីៈ ទុកឲ្យកូនអស់ហើយ?

មិលៈ ចែកកូនអស់ហើយ បានម្នាក់១ប្លង់ ។

ដានីៈ អត់ចង់ទៅស្រុកវិញដោយសារស្តាយដីនៅនេះ?

មិលៈ ស្តាយដី ស្តាយកូន បើកូនមិនចង់ទៅផង កូនគាត់នៅនេះ ។

ដានីៈ កូនអត់ចង់ទៅ?

មិលៈ ចាំ!

ដានីៈ ដល់អីចឹងក៏អត់ទៅ បើកូនទៅៗវិញ?

មិលៈ ទៅ ទៅចោលកូនយ៉ាងម៉េច នឹកឃើញថាកូនធំៗតែ២គ្រាប់ហ្នឹង ហើយម៉ែទៅចោលនឹកកូនឯនេះ ហើយមានលុយណាយើងមេម៉ាយហ្នឹង ទៅរកលុយឯណា ។

ដានីៈ បើទៅៗតែម្នាក់ឯង កូនអត់ទៅ?

មិលៈ ម្នាក់ឯងក៏អត់ទៅដែរ ។

ដានីៈ ទាល់តែទៅទាំងអស់គ្នា?

មិលៈ ទៅទាំងអស់ ។

ដានីៈ បើកូនអត់ព្រមទៅ?

មិលៈ កូនវានឹកគ្នាវានៅទៅ សុខចិត្តនៅចាប់នឹងកូនហ្នឹងទៅ ។

ដានីៈ តែលោកយាយធ្លាប់ទៅលេងស្រុកដែរ?

មិលៈ ខ្ញុំទៅបានតែម្តង ។

ដានីៈ ទៅយូរនៅ?

មិលៈ យូរហើយ ៣-៤ឆ្នាំហើយ ។

ដានីៈ ទៅបានជួបបងប្អូនដែរ?

មិលៈ ជួប មិនលឺខ្ញុំថាចាស់ហើយបងខ្ញុំនោះ ដើរកោងៗ ។

ដានីៈ អត់ដែលនាំគាត់មកលេង?

មិលៈ អត់មកទេ គាត់មិនមកទេ អត់លុយ ។

ដានីៈ យាយមានគិតថាទៅលេងទៀតទេ?

មិលៈ អត់ទេ ។

ដានីៈ អត់ចង់ទៅទៀតទេ?

មិលៈ លែងចង់ទៅ មិនមែនតិចលុយទេ ។

ដានីៈ អស់ច្រើន ។

មិលៈ ទៅម្តងអស់៥០-៦០ម៉ឺន ទៅរកឯណាយើងចាស់ប៉ុណ្ណេះហើយ ទៅរកលុយឯណាបាន ផ្លូវជិតនឹងទៅក្តារមឈូសហើយ ទៅណារួច មានអ្នកណាឲ្យលុយបើកូនច្រើនទៅ ចេះតែកូននេះឲ្យ១០ម៉ឺន កូននោះឲ្យ១០ម៉ឺន ហើយចុះខ្ញុំមេម៉ាយទៅរកលុយឯណា នៅជាមួយព្រះសង្ឃ ដូចថាឃ្លានភេសជ្ជៈលោកឲ្យ២-៣ពាន់ចាយទៅ ស៊ីទៅ កូនហើយខ្ញុំទៅរកលុយឯណា ។

ដានីៈ ដល់ពេលលោកយាយខានិយាយភាសាជនជាតិភ្លេចអស់?

មិលៈ ភ្លេចអស់ ។

ដានីៈ ជនជាតិការីតលោកយាយ និយាយតែខ្មែរឥឡូវ?

មិលៈ ចុះបើនៅរួមរស់ជាមួយខ្មែរ យើងនិយាយខ្មែរ ។

ដានីៈ អត់មានអារម្មណ៍នឹកស្រុក បងប្អូនជនជាតិយើង?

មិលៈ ខ្ញុំអារម្មណ៍ដែរ ខ្ញុំវាអត់លុយ អត់លុយទៅ ទៅម្តងឡើង៥០-៦០ម៉ឺនទៅរកឯណា ។

ដានីៈ កាលទៅមុនហ្នឹងទៅនៅបានយូរទេ?

មិលៈ	អានេះខ្ញុំលក់ដីខ្ញុំមួយប្លង់អស់ហើយ បាន២៨ម៉ឺននោះទៅ មកវិញអត់មានសោហ៊ុយមកផ្ទះទៀត អត់គ្រាន់ ។

ដានីៈ	ធ្វើម៉េចបានមក?

មិលៈ	វាឆ្ងាយពេក អត់គ្រាន់ ។

ដានីៈ	ធ្វើម៉េចបានមកវិញបាន?

មិលៈ	បានគេចងដៃ ចងជើង គេនឹកប្អូនគេហ្នឹង ដូចថាបង១ដីដូនមួយ ដីទួតមួយគេចងដៃ គេដាក់លុយ១-២ពាន់ បានលុយ១៥០០ទៅបានមកវិញ បានទៅរួច មានអីណាកូនឯងមើល ។

ដានីៈ	ទៅបានមកវិញ កាលទៅតែម្នាក់ឯងទេ កូនអត់ទៅជាមួយ?

មិលៈ	ទៅតែម្នាក់ បើកូនទៅជាមួយកាន់តែច្រើនណាស់លុយ ៣នាក់ម៉ែកូនហោចណាស់២-៣លានហ្នឹងណា៎ តែកូនវាមិនចង់ទៅ ឲ្យម៉ែទៅសាកមើល ។

ដានីៈ	កូនគាត់ធូរធារទេកូនលោកយាយ?

មិលៈ	ទេ ក្នាក្រ រកអីបានហ្នឹង ផ្ទះនៅ នៅតែតូប ធ្វើតូបប្រហ៊ុននេះក្រោម បាយនៅហ្នឹង ដេកនៅហ្នឹង មិនដឹងឆ្នាំងបាយ មិនដឹងឆ្នាំស្លរទេ ដូចគ្រែប៉ុណ្ណេះទុកសំរាប់ដាក់ឆ្នាំងបាយ ឆ្នាំងស្លរ

ដានីៈ	កាលពីម្ដាយលោកយាយស្លាប់ អត់បានដឹងថាគាត់ស្លាប់?

មិលៈ	អត់ដឹងទេ យើងនៅកំពុងកើតសង្គ្រាមយើងអត់ទាន់ដឹង ។

ដានីៈ	លោកយាយតាមខ្មែរក្រហមរហូត?

មិលៈ	ចា៎!

ដានីៈ	លោកយាយម៉េចដែររស់នៅដោយសាសង្គ្រាម បែកស្រុក បែកភូមិ លោកយាយមានអារម្មណ៍យ៉ាងម៉េច?

មិលៈ	អត់ទេ ដឹងតែពីសប្បាយ ។

ដានីៈ	ម៉េចបានសប្បាយ?

មិលៈ	ឃើញគេសប្បាយៗតាមគេទៅ ។

ដានីៈ	ពីណាសប្បាយ?

មិលៈ	សប្បាយឃើញញាតិមិត្តជិតខាង ។

ដានីៈ	អត់ព្រួយ អត់បារម្ភ?

មិលៈ	អត់ទេ ក្នុងចិត្តអត់ព្រួយទេ គេងាប់ឯងងាប់ដែលទៅ គេរស់ឯងរស់ដែរ ។

ដានីៈ	ចុះហូបចុកបានគ្រប់គ្រាន់ដែលអត់កាលនៅជាមួយខ្មែរក្រហម?

មិលៈ មិនសូវខ្វះអីអង្ករគេបើកក្នុង១ខែ២-៣ដង ថៃគេឲ្យ ទឹកដោះគោ ស្ករស ត្រីខ ថៃគេឧបត្ថម្ភជាប់ហើយ ។

ដានីៈ ឥឡូវម៉េចដែរ? ឥឡូវលំបាកអត់?

មិលៈ ឥឡូវក៏មិនខ្វះដែរ ។

ដានីៈ ឥឡូវសំបូរដែរ?

មិលៈ សំបូរដូចគ្នា ។

ដានីៈ ម៉េចអីចឹង?

មិលៈ គេលក់តាមភូមិ តាមឃុំ យើងទិញត្រីរបស់វាទៅ ទិញស្ពឺៗរបស់វាទៅ ដូចជាមី ដូចជាត្រីខ

ដានីៈ ដូចថាយើងទិញទាល់តែមានលុយ មានកាក់អីដែរបានគេលក់ឲ្យ?

មិលៈ ហ្នឹងហើយ លុយដូចថាយើងបានចិញ្ចឹមជ្រូក ចិញ្ចឹមមាន់ យើងលក់ទៅបាន៤-១០ម៉ឺន មួយឆ្នាំពេទ្យកូនឈឺ យើងគិតបែងចែកច្រើនណាស់ ។

ដានីៈ លោកយាយគិតថាកាលពីមុន ហើយឥឡូវរស់នៅមួយណាស្រួលជាង? កាលពីលោកយាយនៅជាមួយខ្មែរក្រហមនៅតាមភ្នំ នៅជាំស្វា ហើយឥឡូវ មកដល់បច្ចុប្បន្ននេះមួយណាស្រួលជាង?

មិលៈ អត់ដឹងស្រួលដឹងអីទេខ្ញុំ ដឹងតែកន្លែងណាមានស៊ី មានចុកនៅហ្នឹងឯង ។ កន្លែងណាមានហូប មានចុក មានសប្បាយហ្នឹងនៅកន្លែងហ្នឹងឯង ។

ដានីៈ លោកយាយស្គាល់តាម៉ុក ទេ?

មិលៈ ស្គាល់តែមុខទេ ។

ដានីៈ ដែលជួបគាត់បាននិយាយជាមួយគាត់ទេ?

មិលៈ អត់ទេ បានតែលឺល្បីថាតាម៉ុកៗ ខ្ញុំឃើញតែម្តងទេ ។

ដានីៈ តាម៉ុក ម៉េចទៅរាងគាត់?

មិលៈ គាត់ចាស់ហើយ អង្កុតជើងម្ខាង ។

ដានីៈ គាត់ស្លូតឬកាច តាម៉ុក?

មិលៈ ពិការ ។

ដានីៈ គាត់ស្លូតឬកាច?

មិលៈ កាច ។

ដានីៈ កាចម៉េចទៅតាមលោកយាយដឹង?

មិលៈ មិនកាចប៉ុន្មានទេ បើថាឲ្យនេះ ឲ្យនោះគេហ្នឹង បើយើងក្រយកហ្នឹងគាត់យកមកវិញ ប៉ុណ្ណោះឯង ។

ដានីៈ ម៉េចលោកយាយដឹង?

មិលៈ ដូចថាឲ្យលុយ៥ម៉ឺនអីចឹងទៅ តែយើងក្រយកពីគាត់ណាស់ គាត់យកពីយើងវិញ ។

ដានីៈ ម៉េចអីចឹង?

មិលៈ អត់ដឹង ។

ដានីៈ ម៉េចលោកយាយដឹងរឿងតាម៉ុក?

មិលៈ យើងជួបតែម្ដងៗ វាមិនបានជួបរាល់ថ្ងៃ ។

ដានីៈ គាត់ធ្លាប់ឲ្យលុយលោកយាយដែរ?

មិលៈ អត់ទេ មិនដែលបានឲ្យមួយរៀលផង ។

ដានីៈ ម៉េចដឹងថាគាត់បើយើងក្រយក?

មិលៈ ខ្ញុំលឺគេថាដែរ តែខ្ញុំជួបគាត់តែម្ដងៗហ្នឹង ។

ដានីៈ ជួបបាននិយាយជាមួយគាត់ដែលអត់?

មិលៈ អត់ទេ ។

ដានីៈ អត់បាននិយាយទេ?

មិលៈ អត់បាននិយាយ ។

ដានីៈ ដឹងតែគាត់កាច?

មិលៈ គេថាកាចៗតាមគេដែលទៅ ។

ដានីៈ ចុះតាប៉ុល ពត ដែលជួបគាត់?

មិលៈ អត់ជួបទេ មិនដែលបានជួបផង ។

ដានីៈ តាសុន សេន អី?

មិលៈ អត់ទេ ។

ដានីៈ មេៗអត់ដែលជួប?

មិលៈ លឺតែឈ្មោះ តែមិនដឹងមុខម៉េចផង ខ្ញុំអត់ដឹងដែរ ។

ដានីៈ ចុះតាសារឿន ដែលជួបគាត់អត់?

មិលៈ តាសារឿន ខ្ញុំមិនបានជួបទេ ជួបតែម្ដង ។

ដានីៈ ជួបគាត់នៅណា?

មិលៈ នៅនឹងភូមិគាត់នេះ ។

ដានី: ណាភូមិគាត់?

មិល: ហ្នឹងភូមិទំនប់ដាច់ហ្នឹង ។

ដានី: ភូមិទំនប់ដាច់ ភូមិគាត់?

មិល: ហ្នឹងហើយ ។

ដានី: ចុះតាសាន?

មិល: ទេ ខ្ញុំមិនស្គាល់ទេ ។ ខ្ញុំកំរណាស់រឿងខ្ញុំអត់បានស្គាល់ពីណាមួយទេ បានតែមួយៗហ្នឹងឯង ។

ដានី: លោកយាយមកនៅវត្តអីចឹងយល់ឃើញថាម៉េច យល់ឃើញថាដោយសារ មុិញលោកយាយមានប្រសាសន៍ថាចង់នៅវត្ត ដើម្បីបំណង ។

មិល: ចង់បានបុណ្យ យើងអត់បានធ្វើបុណ្យពីជាតិមុនយើងក្រ អីចឹងយើងមានព្រះពុទ្ធសាសនា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហ្នឹងយើងចេះចង់ធ្វើទៅ យើងទៅនៅជាមួយកូនយ៉ាងម៉េចបើចាស់ចំណាស់ហ្នឹងហើយ មានកូនណាជួយម៉ែរួចទេ មានតែព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនេះឯងដែលជួយរួច ជួយខ្ញុំរួច ។

ដានី: អ៊ំជឿលើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជឿតាំងពីអង្កាល់មក? ទើបតែជឿឥឡូវ ឬជឿតាំងពីក្មេងៗមក?

មិល: ជឿតាំងពីម៉ែឪយើងពីដើម គេប្រាប់ ។

ដានី: ម៉ែឪលោកយាយកាលនៅស្រុក ។

មិល: នៅតូចៗប៉ុណ្ណេះ ។

ដានី: នៅប៉ុណ្ណេះគាត់ប្រាប់ដែរ?

មិល: ប្រាប់កាលយើងមិនទាន់ចេញពីគាត់ហ្នឹង ។

ដានី: គាត់ប្រាប់ថាម៉េច?

មិល: គាត់ថាកូនអើយយើងកើតមកមានតែព្រះពុទ្ធ ព្រះសង្ឃ ព្រះធម៌ ដែលអាចយិតយោងសណ្ដោងកូនឯងរួច ។

ដានី: កាលពីលោកយាយនៅស្រុកកំណើតនោះ វត្តនៅឆ្ងាយសឹងអី អត់សូវបានវត្តផងហ្នឹង?

មិល: ចុះនៅក្មេង ម៉េចចូលវត្តបាន ។

ដានី: អីចឹងលោកយាយមានបំណងប្រាថ្នាយ៉ាងម៉េចទៀត ពីឥឡូវទៅមុខទៀត?

មិល: អត់មានទេ បំណងប្រាថ្នាយ៉ាងម៉េចទៀតបើចាស់ នៅចាំតែថ្ងៃក្ដាមឈូសនោះ ។

ដានី: អីចឹងខ្ញុំអរគុណច្រើនលោកយាយ ។

មិល: ចា៎! **ចប់**